ក្រសួងអប់រំ យុវជន និងកីឡា

គណិតវិទ្យា ថ្នាក់ទី៣

ប៤

# សៀវភៅលំហាត់




ហាមលក់
NOT FOR SALE

ប ៤

មេរៀន

## ទី១១ ដល់ ទី១៣

កូនស្វាឆ្លាត

# មេរៀនទី 11 វិធីចែក

## រំឭកទំនាក់ទំនងរវាងវិធីដក និងវិធីចែក

**គួរចងចាំ**

ពូឈានមានពងមាន់ 12គ្រាប់។ គាត់ចង់រៀបដាក់ក្នុងមួយប្រអប់ 4គ្រាប់ស្មើៗគ្នា។ តើគាត់ត្រូវការប្រអប់ចំនួនប៉ុន្មាន?



12 - 4 = 8
8 - 4 = 4
4 - 4 = 0
ឬ 12 - 4 - 4 - 4 = 0

គាត់ត្រូវការ 3ប្រអប់។

12 ÷ 4 = 3

តំណាំងចែក ↑ 12, តួចែក ↑ 4, ផលចែក ↑ 3




យើងសរសេរជាល្បះលេខចែកគឺ៖

**12 ÷ 4 = 3**

អានថា៖ **12 ចែក 4 ស្មើនឹង 3**។

មើលវីដេអូ

ចូរអានចំណោទខាងក្រោម រួចគណនារកផលចែក និងបំពេញចំនួនក្នុងប្រអប់

**ឧទាហរណ៍**

ពូឈានមានពងមាន់ចំនួន 10ប្រអប់។ ភ្ញៀវម្នាក់ទិញ 2ប្រអប់។ តើគាត់លក់ឱ្យភ្ញៀវបានប៉ុន្មាននាក់?



[10] ÷ [2] = [5] គាត់លក់ឱ្យភ្ញៀវបាន [5] នាក់។

១) អ្នកលក់ម្នាក់មានសម្បកកង់រថយន្តចំនួន 32។ រថយន្តមួយគ្រឿងត្រូវការសម្បកកង់ចំនួន 4។ តើគាត់ដាក់បានចំនួនរថយន្តប៉ុន្មានគ្រឿង?

[ ] ÷ [ ] = [ ] គាត់ដាក់បានរថយន្តចំនួន [ ] គ្រឿង។



២) មីងវីណាចែកឃ្លីចំនួន 18គ្រាប់ឱ្យកុមារ 3នាក់ស្មើៗគ្នា។ តើកុមារម្នាក់ៗទទួលបានឃ្លីចំនួនប៉ុន្មានគ្រាប់?

[ ] ÷ [ ] = [ ] កុមារម្នាក់ៗទទួលបានឃ្លីចំនួន [ ] គ្រាប់។



៣) សុក និងចិន្តាដកស្ពៃបានចំនួនស្មើៗគ្នាសរុប 14គុម្ព។ តើម្នាក់ៗដកស្ពៃបានប៉ុន្មានគុម្ព?



[ ] ÷ [ ] = [ ] ម្នាក់ៗដកស្ពៃបានចំនួន [ ] គុម្ព។

៤) កូនមាន់សរុបមានចំនួន 25ក្បាល ហើយមេមាន់មួយមានកូន 5ក្បាល។ តើមេមាន់ទាំងអស់មានចំនួនប៉ុន្មានក្បាល?



[ ] ÷ [ ] = [ ] មេមាន់ទាំងអស់មានចំនួន [ ] ក្បាល។

៥) ចិន្តាមានស្ករគ្រាប់ចំនួន 16គ្រាប់។ គាត់ចែកស្ករគ្រាប់នោះឱ្យខ្លួនគាត់និងមិត្តភក្តិ 3នាក់ទៀតក្នុងចំណែកស្មើៗគ្នា។ តើម្នាក់ទទួលបានស្ករគ្រាប់ចំនួនប៉ុន្មានគ្រាប់?



[ ] ÷ [ ] = [ ] ម្នាក់ៗទទួលបានស្ករគ្រាប់ចំនួន [ ] គ្រាប់។


facebook.com/moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ពាក្យដែលប្រើក្នុងប្រមាណវិធីចែក

**គួរចងចាំ**



ចែកជា 4ចំណែក ស្មើៗគ្នា

**12 ÷ 4 = 3**

12 → **តំណាំងចែក**, 4 → **តួចែក**, 3 → **ផលចែក**



តំណាំងចែក ← 12 | 4 → តួចែក

- 12 | 3 → ផលចែក

សំណល់ ← 0



1. ចូរបំពេញប្រអប់ដោយប្រើពាក្យ **តំណាំងចែក តួចែក ផលចែក** ឬ**សំណល់**

ក) 49 ÷ 7 = 7

49 ↑ តំណាំងចែក, 7 ↑ [ ], 7 ↑ ផលចែក

ខ) [ ] → 56 | 3 ← តួចែក

- 56 | 7 ← [ ]

[ ] → 0

គ) [ ] 45 | 9 [ ]

- 45 | 5 [ ]

[ ] 0

ឃ) 63 ÷ 7 = 9

[ ] តួចែក [ ]

មើលវីដេអូ

---

2. ចូរអានចំណោទ និងបំពេញចំនួនក្នុងប្រអប់ រួចគណនារកផលចែក

មើលវីដេអូ

ក) អ្នកលក់មានផ្កា 20ទងលក់ឱ្យភ្ញៀវ 4នាក់ស្មើៗគ្នា។ តើភ្ញៀវម្នាក់ៗទទួលបានផ្កាប៉ុន្មានទង?

[ ] ÷ [ ] = [ ]

តំណាំងចែក តួចែក ផលចែក



តំណាំងចែក [ ] | [ ] តួចែក

- [ ] | [ ] ផលចែក

សំណល់ [ ]

ខ) ពូឈានមានពងមាន់ 60គ្រាប់។ គាត់ចង់រៀបពងមាន់ដាក់ក្នុងមួយប្រអប់ 10គ្រាប់ស្មើៗគ្នា។ តើគាត់ត្រូវការប្រអប់ចំនួនប៉ុន្មាន?

តំណាំងចែក [ ] | [ ] តួចែក

- [ ] | [ ] ផលចែក

សំណល់ [ ]



[ ] ÷ [ ] = [ ]

តំណាំងចែក តួចែក ផលចែក

គ) គេមានស្ករគ្រាប់ 16គ្រាប់។ គេចែកឱ្យក្មេង 8នាក់ស្មើៗគ្នា។ តើម្នាក់ៗទទួលបានស្ករគ្រាប់ចំនួនប៉ុន្មានគ្រាប់?

[ ] ÷ [ ] = [ ]

តំណាំងចែក តួចែក ផលចែក



តំណាំងចែក [ ] | [ ] តួចែក

- [ ] | [ ] ផលចែក

សំណល់ [ ]

# រំឭកទំនាក់ទំនងរវាងវិធីគុណនិងវិធីចែក

**គួរចងចាំ**



ចែកជា ... យើងបាន

10 ÷ 2 = 5

2ដង ស្មើនឹង

5 x 2 = 10



ចែកជា ... យើងបាន

12 ÷ 4 = 3

4ដង ស្មើនឹង

3 x 4 = 12

10 ÷ 2 = 5 **វិធីចែក៖ ចំនួនធំជាងគេគឺជាតំណាំងចែក** ហើយតែងតែសរសេរមុនគេ។ **12 ÷ 4 = 3**
តំណាំងចែកនិងតួចែក**មិនអាចប្ដូរទីតាំង**បានឡើយ។

**5 x 2 = 10** **វិធីគុណ៖ ចំនួនធំជាងគេគឺ**តែងតែជា**ផលគុណ**ជានិច្ច។ **3 x 4 = 12**
**2 x 5 = 10** តួគុណទាំងពីរ**អាចត្រឡប់**បាន។ **4 x 3 = 12**

មើលវីដេអូ

**គួរចងចាំ**

| |
|---|
| 2 x 1 = 2 |
| 2 x 2 = 4 |
| 2 x 3 = 6 |
| 2 x 4 = 8 |
| 2 x 5 = 10 |
| 2 x 6 = 12 |
| 2 x 7 = 14 |
| 2 x 8 = 16 |
| 2 x 9 = 18 |
| 2 x 10 = 20 |

**14 ÷ 2 = □**

គិតអំពីវិធីគុណ

2 x □ = 14

រកមើលលេខ 14

2 x **7** = 14

តារាងមេគុណអាចជួយយើងក្នុងការធ្វើប្រមាណវិធីចែកបាន។




ដូចនេះ៖ **14 ÷ 2 = 7**

## ចូររកផលចែក

**ឧទាហរណ៍**

12 ÷ 3 = □ គិតអំពីវិធីគុណគឺ 3 x □ = 12 3 x 4 = 12
ដូចនេះ៖ 12 ÷ 3 = 4

មើលវីដេអូ

1.
ក) 12 ÷ 3 = 4
ខ) 18 ÷ 3 = □
គ) 3 ÷ 3 = □
ឃ) 9 ÷ 3 = □
ង) 24 ÷ 3 = □
ច) 15 ÷ 3 = □
ឆ) 30 ÷ 3 = □

2.
ក) 8 ÷ 4 = □
ខ) 16 ÷ 4 = □
គ) 28 ÷ 4 = □
ឃ) 20 ÷ 4 = □
ង) 36 ÷ 4 = □
ច) 24 ÷ 4 = □
ឆ) 4 ÷ 4 = □

3.
ក) 30 ÷ 5 = □
ខ) 45 ÷ 5 = □
គ) 18 ÷ 2 = □
ឃ) 2 ÷ 2 = □
ង) 32 ÷ 4 = □
ច) 12 ÷ 4 = □
ឆ) 27 ÷ 3 = □

4.
ក) 24 ÷ 4 = □
ខ) 30 ÷ 3 = □
គ) 35 ÷ 5 = □
ឃ) 36 ÷ 4 = □
ង) 16 ÷ 2 = □
ច) 21 ÷ 3 = □
ឆ) 50 ÷ 5 = □

# ការប្រើតារាងមេគុណក្នុងវិធីចែក

| | | | |
|---|---|---|---|
| 2 x 1 = 2 | 3 x 1 = 3 | 4 x 1 = 4 | 5 x 1 = 5 |
| 2 x 2 = 4 | 3 x 2 = 6 | 4 x 2 = 8 | 5 x 2 = 10 |
| 2 x 3 = 6 | 3 x 3 = 9 | 4 x 3 = 12 | 5 x 3 = 15 |
| 2 x 4 = 8 | 3 x 4 = 12 | 4 x 4 = 16 | 5 x 4 = 20 |
| 2 x 5 = 10 | 3 x 5 = 15 | 4 x 5 = 20 | 5 x 5 = 25 |
| 2 x 6 = 12 | 3 x 6 = 18 | 4 x 6 = 24 | 5 x 6 = 30 |
| 2 x 7 = 14 | 3 x 7 = 21 | 4 x 7 = 28 | 5 x 7 = 35 |
| 2 x 8 = 16 | 3 x 8 = 24 | 4 x 8 = 32 | 5 x 8 = 40 |
| 2 x 9 = 18 | 3 x 9 = 27 | 4 x 9 = 36 | 5 x 9 = 45 |
| 2 x 10 = 20 | 3 x 10 = 30 | 4 x 10 = 40 | 5 x 10 = 50 |

| | | | |
|---|---|---|---|
| 6 x 1 = 6 | 7 x 1 = 7 | 8 x 1 = 8 | 9 x 1 = 9 |
| 6 x 2 = 12 | 7 x 2 = 14 | 8 x 2 = 16 | 9 x 2 = 18 |
| 6 x 3 = 18 | 7 x 3 = 21 | 8 x 3 = 24 | 9 x 3 = 27 |
| 6 x 4 = 24 | 7 x 4 = 28 | 8 x 4 = 32 | 9 x 4 = 36 |
| 6 x 5 = 30 | 7 x 5 = 35 | 8 x 5 = 40 | 9 x 5 = 45 |
| 6 x 6 = 36 | 7 x 6 = 42 | 8 x 6 = 48 | 9 x 6 = 54 |
| 6 x 7 = 42 | 7 x 7 = 49 | 8 x 7 = 56 | 9 x 7 = 63 |
| 6 x 8 = 48 | 7 x 8 = 56 | 8 x 8 = 64 | 9 x 8 = 72 |
| 6 x 9 = 54 | 7 x 9 = 63 | 8 x 9 = 72 | 9 x 9 = 81 |
| 6 x 10 = 60 | 7 x 10 = 70 | 8 x 10 = 80 | 9 x 10 = 90 |

ចូរបំពេញចំនួនក្នុងប្រអប់

1.
- ក) 12 ÷ 6 = ☐
- ខ) 30 ÷ 6 = ☐
- គ) 48 ÷ 6 = ☐
- ឃ) 24 ÷ 6 = ☐
- ង) 21 ÷ 7 = ☐
- ច) 42 ÷ 7 = ☐
- ឆ) 63 ÷ 7 = ☐
- ជ) 14 ÷ 7 = ☐
- ឈ) 70 ÷ 7 = ☐

2.
- ក) 32 ÷ 8 = ☐
- ខ) 56 ÷ 8 = ☐
- គ) 16 ÷ 8 = ☐
- ឃ) 80 ÷ 8 = ☐
- ង) 8 ÷ 8 = ☐
- ច) 45 ÷ 9 = ☐
- ឆ) 18 ÷ 9 = ☐
- ជ) 81 ÷ 9 = ☐
- ឈ) 27 ÷ 9 = ☐

3.
- ក) 36 ÷ 6 = ☐
- ខ) 49 ÷ 7 = ☐
- គ) 64 ÷ 8 = ☐
- ឃ) 36 ÷ 9 = ☐
- ង) 18 ÷ 6 = ☐
- ច) 40 ÷ 8 = ☐
- ឆ) 63 ÷ 9 = ☐
- ជ) 28 ÷ 7 = ☐
- ឈ) 54 ÷ 6 = ☐

4.
- ក) 30 ÷ 2 = ☐
- ខ) 54 ÷ 9 = ☐
- គ) 24 ÷ 4 = ☐
- ឃ) 35 ÷ 7 = ☐
- ង) 27 ÷ 3 = ☐
- ច) 48 ÷ 8 = ☐
- ឆ) 15 ÷ 5 = ☐
- ជ) 42 ÷ 6 = ☐
- ឈ) 32 ÷ 4 = ☐

# ការរកផលចែកដោយប្រើតារាងគុណ

| x | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|---|
| 1 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| 2 | 2 | 4 | 6 | 8 | 10 | 12 | 14 | 16 | 18 | 20 |
| 3 | 3 | 6 | 9 | 12 | 15 | 18 | 21 | 24 | 27 | 30 |
| 4 | 4 | 8 | 12 | 16 | 20 | 24 | 28 | 32 | 36 | 40 |
| 5 | 5 | 10 | 15 | 20 | 25 | 30 | 35 | 40 | 45 | 50 |
| 6 | 6 | 12 | 18 | 24 | 30 | 36 | 42 | 48 | 54 | 60 |
| 7 | 7 | 14 | 21 | 28 | 35 | 42 | 49 | 56 | 63 | 70 |
| 8 | 8 | 16 | 24 | 32 | 40 | 48 | 56 | 64 | 72 | 80 |
| 9 | 9 | 18 | 27 | 36 | 45 | 54 | 63 | 72 | 81 | 90 |
| 10 | 10 | 20 | 30 | 40 | 50 | 60 | 70 | 80 | 90 | 100 |

**ឧទាហរណ៍**

**27 ÷ 3 = □**

រកមើលតួចែក (3)



រកមើលតំណាំងចែក (27)

**3 x 9 = 27**

ដូចនេះ: **27 ÷ 3 = 9**



**32 ÷ 8 = □**

8 x 4 = 32 **32 ÷ 8 = 4**

1. ចូរប្រើតារាងគុណខាងលើដើម្បីរកផលចែក

ក) 48 ÷ 6 = □ ខ) 12 ÷ 2 = □ គ) 56 ÷ 8 = □ ឃ) 63 ÷ 7 = □

ង) 20 ÷ 5 = □ ច) 7 ÷ 7 = □ ឆ) 54 ÷ 9 = □ ជ) 24 ÷ 8 = □

ឈ) 40 ÷ 4 = □ ញ) 21 ÷ 3 = □ ដ) 36 ÷ 4 = □ ឋ) 18 ÷ 9 = □

មើលវីដេអូ

2. ចូរប្រើតារាងគុណខាងលើដើម្បីរកតួចែក

**ឧទាហរណ៍**

24 ÷ □ = 4

រកមើលផលចែក



រកមើលតំណាំងចែក (24)

4 x 6 = 24

24 ÷ 6 = 4

មើលវីដេអូ

ក) 18 ÷ □ = 9 ខ) 48 ÷ □ = 8 គ) 35 ÷ □ = 7 ឃ) 8 ÷ □ = 2

ង) 42 ÷ □ = 6 ច) 24 ÷ □ = 3 ឆ) 20 ÷ □ = 5 ជ) 36 ÷ □ = 4

ឈ) 27 ÷ □ = 3 ញ) 42 ÷ □ = 7 ដ) 64 ÷ □ = 8 ឋ) 48 ÷ □ = 6

# ហ្វឹកហាត់ការរកផលចែកដោយប្រើតារាងគុណ

1. **ល្បែងគុណនិងចែកចំនួនរីករាយ** (លេងជាដៃគូ)

**សម្ភារៈ៖** ក្ដារឆ្នួនឬក្រដាស តារាងគុណនៅទំព័រ 5

**របៀបលេង៖**

១) ប្ដូរវេនគ្នាធ្វើជា**អ្នកចាប់ផ្ដើម** ម្ដងម្នាក់។

២) **សិស្ស ក** គូរប្រអប់ចំនួនបីនៅលើក្ដារឆ្នួនរបស់ខ្លួន ដោយដាក់សញ្ញាចែកនិងសញ្ញាស្មើនៅចន្លោះប្រអប់នីមួយៗ។

៣) **សិស្ស ខ** គូរប្រអប់ចំនួនបីនៅលើក្ដារឆ្នួនរបស់ខ្លួន ដោយដាក់សញ្ញាគុណនិងសញ្ញាស្មើនៅចន្លោះប្រអប់នីមួយៗ។

៤) **សិស្ស ក** ប្រើតារាងគុណដើម្បីបំពេញល្បះលេខចែករបស់ខ្លួនដោយជ្រើសរើសចំនួនចៃដន្យ។

**សិស្ស ក** | **សិស្ស ខ**

□ ÷ □ = □ | □ x □ = □

36 ÷ 9 = 4

មើលវីដេអូ



| 8 | 9 | 10 |
|---|---|---|
| 8 | 9 | 10 |
| 16 | 18 | 20 |
| 24 | 27 | 30 |
| 32 | 36 | 40 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 3 | 3 | 6 | 9 | 12 | 15 | 18 | 21 | 24 | 27 | 30 |
| 4 | 4 | 8 | 12 | 16 | 20 | 24 | 28 | 32 | 36 | 40 |
| 5 | 5 | 10 | 15 | 20 | 25 | 30 | 35 | 40 | 45 | 50 |

| x | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|---|
| 1 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| 2 | 2 | 4 | 6 | 8 | 10 | 12 | 14 | 16 | 18 | 20 |
| 3 | 3 | 6 | 9 | 12 | 15 | 18 | 21 | 24 | 27 | 30 |
| 4 | 4 | 8 | 12 | 16 | 20 | 24 | 28 | 32 | 36 | 40 |
| 5 | 5 | 10 | 15 | 20 | 25 | 30 | 35 | 40 | 45 | 50 |
| 6 | 6 | 12 | 18 | 24 | 30 | 36 | 42 | 48 | 54 | 60 |

៥) **សិស្ស ខ** ប្រើតារាងគុណដើម្បីពិនិត្យមើលផលចែក និងបំពេញល្បះលេខគុណរបស់ខ្លួន។

4 x 9 = 36

៦) **ទាំងពីរនាក់**ផ្ទៀងផ្ទាត់មើលឱ្យប្រាកដថាផលគុណមានតម្លៃស្មើគ្នាជាមួយតំណាំងចែក។

៧) ប្ដូរវេនគ្នាធ្វើជាអ្នកចាប់ផ្ដើមឱ្យបានម្នាក់យ៉ាងតិចបីដង។

36 ÷ 9 = 4 ✓ | 4 x 9 = 36 ✓

---

2. ចូរប្រើតារាងគុណដើម្បីផ្ទៀងផ្ទាត់ផលចែក និងគូស ✓ បើវាត្រឹមត្រូវ ឬគូស X បើវាខុស។

ក) 18 ÷ 6 = 3 □ ខ) 58 ÷ 8 = 7 □

គ) 42 ÷ 8 = 5 □ ឃ) 18 ÷ 2 = 9 □

ង) 25 ÷ 5 = 5 □ ច) 48 ÷ 6 = 8 □

ឆ) 36 ÷ 4 = 9 □ ជ) 72 ÷ 9 = 6 □

ឈ) 18 ÷ 9 = 3 □ ញ) 49 ÷ 7 = 7 □

ដ) 28 ÷ 4 = 7 □ ឋ) 24 ÷ 6 = 3 □

**ឧទាហរណ៍**

15 ÷ 4 = 3 X

30 ÷ 6 = 5 ✓

លំហាត់ណាខ្លះត្រឹមត្រូវទៅហ្ន៎?

មើលវីដេអូ



# ការចែកចំនួនគត់មានលេខ 2ខ្ទង់នឹង 1ខ្ទង់គ្មានសំណល់

**គួរចងចាំ**

ពូឈានលក់ពងមាន់ 54គ្រាប់ឱ្យទៅភ្ញៀវ 3នាក់ស្មើៗគ្នា។ តើភ្ញៀវម្នាក់ៗទិញបានពងមាន់ប៉ុន្មានគ្រាប់?

មើលវីដេអូ

54 | 3

**ជំហានទី១៖**
ចែកខ្ទង់ដប់។ 5 ÷ 3 = 1 សរសេរលេខ 1 នៅខាងផលចែក។

```
54 | 3
   |____
   |
```

**ជំហានទី២៖**
យក 1 x 3។ 1 បីដង 3 សរសេរលេខ 3 នៅក្រោមលេខ 5 រួចដាក់សញ្ញាដក និងធ្វើប្រមាណវិធីដក។
5 ដក 3 នៅសល់ 2។ សរសេរលេខ 2។

```
  54 | 3
- 3  |____
  2  | 1
```

**ជំហានទី៣៖**
ទម្លាក់ខ្ទង់រាយចុះ៖ យើងបាន 24។
24 ចែកឱ្យ 3 បាន 8។
សរសេរលេខ 8។

```
  54 | 3
- 3↓ |____
  24 | 18
```

**ជំហានទី៤៖**
យក 8 x 3។ 8 បីដង 24 សរសេរលេខ 24 រួចដាក់សញ្ញាដក។
24 ដក 24 នៅសល់ 0។
សរសេរលេខ 0។
ដូចនេះ៖ 54 ÷ 3 = 18 ។

```
  54 | 3
- 3  |____
  24 | 18
- 24 |
   0 |
```



ភ្ញៀវម្នាក់ៗទិញបានពងមាន់ចំនួន 18គ្រាប់។

ចូរធ្វើប្រមាណវិធីចែក

ក) 86 | 2

ខ) 72 | 3

គ) 78 | 6

ឃ) 98 | 7

ង) 85 | 5

ច) 92 | 4

ឆ) 96 | 8

ជ) 54 | 2

# ហ្វឹកហាត់ការចែកចំនួនគត់មានលេខ 2ខ្ទង់នឹង 1ខ្ទង់គ្មានសំណល់

មើលវីដេអូ

1. ចូរធ្វើប្រមាណវិធីចែក

ក)



ខ)



គ)



ឃ)



---

2. **ល្បែងស្វែងរកអ្នកឈ្នះ** (លេងជាដៃគូ ឬក្រុមតូច )

មើលវីដេអូ

**សម្ភារៈ៖** ក្ដារឆ្នួន ឬក្រដាសសម្រាប់កត់ត្រា

**របៀបលេង៖**

១) ប្ដូរវេនគ្នាបង្វិលថាសណាមួយដែលខ្លួនពេញចិត្ត។

២) ធ្វើប្រមាណវិធីចែកនៅលើក្ដារឆ្នួនរៀងៗខ្លួន និងផ្ទៀងផ្ទាត់ចម្លើយគ្នាទៅវិញទៅមក។

៣) អ្នកដែលទទួលមានផលចែកធំជាងគេ ទទួលបាន 1ពិន្ទុ។

៤) ប្ដូរថាសបង្វិលគ្នារហូតដល់មានអ្នកដែលទទួលបាន 3ពិន្ទុមុនគេ គឺជា**អ្នកឈ្នះ**។




÷ 6




÷ 5




÷ 7

**ឧទាហរណ៍**



# ការចែកចំនួនគត់មានលេខ 2ខ្ទង់នឹង 1ខ្ទង់មានសំណល់

**គួរចងចាំ**

មីងជានីចែកឃ្លី 34គ្រាប់ឱ្យទៅកុមារ 5នាក់ស្មើៗគ្នា។ តើកុមារម្នាក់ៗទទួលបានឃ្លីចំនួនប៉ុន្មានគ្រាប់? តើឃ្លីនៅសល់ប៉ុន្មានគ្រាប់?






```
 34 | 5
-30 | 6
  4 |
```

**34 ÷ 5 = 6 សំណល់ 4**

មើលវីដេអូ

ដូចនេះកុមារម្នាក់ៗទទួលបានឃ្លីចំនួន 6គ្រាប់។ ហើយឃ្លីនៅសល់មានចំនួន 4គ្រាប់។

1. ចូរធ្វើប្រមាណវិធីចែក

**ឧទាហរណ៍**

```
38 | 7
```

```
 38 | 7
-35 | 5  សំណល់ 3
  3 |
```

38 ÷ 7 = 5 សំណល់ 3

**38 ÷ 7**
តើ 38 មាន 7 ប៉ុន្មានដង? មាន 5ដង។
5 x 7 = 35។ 38 - 35 = 3។
សរសេរលេខ 3



ក) 26 | 6 ខ) 57 | 9 គ) 44 | 5 ឃ) 36 | 7 ង) 29 | 8

ច) 15 | 4 ឆ) 47 | 8 ជ) 38 | 6 ឈ) 70 | 9 ញ) 39 | 5

2. ចូរដោះស្រាយចំណោទខាងក្រោម



មើលវីដេអូ

១) ធីតាមានផ្កាទាំងអស់ចំនួន 32ទង។ នាងរៀបដាក់ក្នុងមួយថូ 6ទងស្មើៗគ្នា។

ក) តើធីតារៀបផ្កាបានចំនួនប៉ុន្មានថូ? ☐ ខ) តើផ្កានៅសល់មានចំនួនប៉ុន្មានទង? ☐



២) ពូសំមានត្រីចំនួន 34គីឡូក្រាម។ គាត់ចែកឱ្យទៅមិត្តភ្ភិរបស់គាត់ម្នាក់ៗចំនួន 5គីឡូក្រាម។

ក) តើគាត់ចែកត្រីឱ្យទៅមិត្តភក្តិបានប៉ុន្មាននាក់? ☐ ខ) តើត្រីនៅសល់ប៉ុន្មានគីឡូក្រាម? ☐

# ការចែកចំនួនគត់មានលេខ 2ខ្ទង់នឹង 1ខ្ទង់មានសំណល់ (ត)

**គួរចងចាំ**

ពូសិដ្ឋមានស្វាយចំនួន 82ផ្លែ។ គាត់រៀបដាក់ក្នុងមួយថង់ 6ផ្លែស្មើៗគ្នា។ តើគាត់ត្រូវការថង់ចំនួនប៉ុន្មាន? តើស្វាយនៅសល់មានចំនួនប៉ុន្មានផ្លែ?

```
 82 | 6
- 6 |----
 -- | 13
 22 |
-18 |
 -- |
  4 |
```



**82 ÷ 6**

តើ 8 ចែក 6 បានប៉ុន្មានដង? បានម្តង។ សរសេរលេខ 1។ 1 ប្រាំមួយដង 6។ 8 ដក 6 នៅសល់ 2 សរសេរលេខ 2។ 2 ទម្លាក់ចុះ យើងបាន 22។ តើ 22 ចែក 6 បានប៉ុន្មានដង? បាន 3ដង។ 3 ប្រាំមួយដង 18។ 22 ដក 18 នៅសល់ 4 សរសេរលេខ 4។

82 ÷ 6 = 13 សំណល់ 4



**ពូសិដ្ឋត្រូវការថង់ចំនួន 13។**



**ស្វាយនៅសល់ 4ផ្លែ។**

ចូរធ្វើប្រមាណវិធីចែក

មើលវីដេអូ

ក) 76 | 3

ខ) 87 | 6

គ) 86 | 4

ឃ) 89 | 5

ង) 97 | 7

ច) 77 | 2

ឆ) 89 | 3

ជ) 75 | 4

# ហ្វឹកហាត់ការចែកចំនួនគត់មានលេខ 2ខ្ទង់នឹង 1ខ្ទង់មានសំណល់

**ល្បែងស្វែងរកអ្នកទាត់បាល់បញ្ចូលទី** ( លេងម្នាក់ឯង ឬជាដៃគូ )

មើលវីដេអូ

**របៀបលេង៖**

១) ប្តូរវេនគ្នាជ្រើសរើសល្បះលេខនៅខាងក្រោម និងគណនារកផលចែក។

២) ផ្ទៀងផ្ទាត់ផលចែកទៅនឹងចំនួននៅលើបាល់។ បើដូចគ្នា ឆូតបាល់នោះបញ្ជាក់ថាអ្នកបានទាត់ចូលទី 1គ្រាប់។

៣) អ្នកដែលឆូតបានច្រើនជាងគេ គឺជា**អ្នកឈ្នះ**។








ក) 92 | 6

ខ) 78 | 3

គ) 86 | 3

ឃ) 54 | 4

ង) 84 | 6

ច) 92 | 7

ឆ) 96 | 6

ជ) 53 | 3

ឈ) 92 | 4

ញ) 72 | 6

ដ) 54 | 3

ឋ) 57 | 2

ឌ) 75 | 7

ឍ) 76 | 4

# ការចែកចំនួនគត់មានលេខ 3ខ្ទង់នឹង 1ខ្ទង់គ្មានសំណល់

**គួរចងចាំ**

អ្នកលក់មានទឹកសុទ្ធ 468ធុង។ គាត់រៀបដាក់ចូលក្នុងរថយន្តចំនួន 3គ្រឿងស្មើៗគ្នា។ តើរថយន្តនីមួយៗដឹកទឹកសុទ្ធចំនួនប៉ុន្មានធុង ?





```
 468 | 3
- 3  |----
 ---  156
  16
- 15
 ---
  18
- 18
 ---
   0
```



តើ 4 ចែកឱ្យ 3 បានប៉ុន្មានដង? បានម្តង។ សរសេរលេខ 1។ 1 បីដង 3។ 4 ដក 3 នៅសល់ 1 សរសេរលេខ 1។ 6 ទម្លាក់ចុះ យើងបាន 16។ តើ 16 ចែកឱ្យ 3 បានប៉ុន្មានដង? បាន 5ដង។ 5 បីដង 15។ 16 ដក 15 នៅសល់ 1 សរសេរលេខ 1។ 8 ទម្លាក់ចុះ យើងបាន 18។ តើ 18 ចែក 3 បានប៉ុន្មានដង? បាន 6ដង។ 6 បីដង 18។ 18 ដក 18 នៅសល់ 0 សរសេរលេខ 0។

$468 \div 3 = 156$

ដូចនេះរថយន្តនីមួយៗដឹកទឹកបាន 156ធុង។



មើលវីដេអូ

ចូរធ្វើប្រមាណវិធីចែក និងបំពេញផលចែកក្នុងប្រអប់

ក) 645 | 5



ខ) 732 | 6



គ) 534 | 3



ឃ) 632 | 2



ង) 896 | 7



ច) 940 | 4



ឆ) 968 | 8



ជ) 780 | 5



ឈ) 574 | 2



# ការចែកចំនួនគត់មានលេខ 3ខ្ទង់នឹង 1ខ្ទង់គ្មានសំណល់ (ត)

**គួរចងចាំ**

ពូរ៉េតកាច់ពោត 4ថ្ងៃបាន 432ផ្លែ។ នៅថ្ងៃនីមួយៗគាត់កាច់ពោតបានក្នុងចំនួនស្មើៗគ្នា។ តើក្នុងមួយថ្ងៃគាត់កាច់ពោតបានចំនួនប៉ុន្មានផ្លែ?

```
 432 | 4
- 4  |108
  03
-  0
   32
 - 32
    0
```

**432 ÷ 4 = 108**






**ដូចនេះពូរ៉េតកាច់ពោតក្នុងមួយថ្ងៃបាន 108ផ្លែ។**

## ល្បែងផ្គូផ្គងសត្វស្វាជាមួយផ្លែពោត

**របៀបលេង៖**

១) ធ្វើប្រមាណវិធីចែក រួចផ្គូផ្គងផលចែកជាមួយផ្លែពោត និងផាត់ពណ៌ផ្លែពោតនោះ។

២) ចំនួននៅលើផ្លែពោតដែលនៅសល់គឺ [ ]

មើលវីដេអូ











ក) 321 | 3

ខ) 944 | 4

គ) 750 | 6

ឃ) 672 | 2













ង) 889 | 7









ច) 954 | 9

ឆ) 512 | 2

ជ) 975 | 3






# ការចែកចំនួនគត់មានលេខ 3ខ្ទង់នឹង 1ខ្ទង់មានសំណល់

**គួរចងចាំ**

សិប្បកម្មផលិតនំមួយកន្លែងលក់នំ 539 ឱ្យទៅហាងចំនួន 4 ស្មើៗគ្នា។ តើហាងនីមួយៗទទួលបាននំចំនួនប៉ុន្មាន ? តើនំនៅសល់មានចំនួនប៉ុន្មាន ?



```
 539 | 4
- 4  |----
 13  | 134
- 12
  19
- 16
   3
```

តើ 5 ចែកឱ្យ 4 បានប៉ុន្មានដង? បានម្ដង។ សរសេរលេខ 1។ 1 បួនដង 4។ 5 ដក 4 នៅសល់ 1 សរសេរលេខ 1។ 3 ទម្លាក់ចុះ យើងបាន 13។ តើ 13 ចែកឱ្យ 4 បានប៉ុន្មានដង? បាន 3ដង។ 3 បួនដង 12។ 13 ដក 12 នៅសល់ 1 សរសេរលេខ 1។ 9 ទម្លាក់ចុះ យើងបាន 19។ តើ 19 ចែកឱ្យ 4 បានប៉ុន្មានដង? បាន 4ដង។ 4 បួនដង 16។ 19 ដក 16 នៅសល់ 3 សរសេរលេខ 3។



ដូចនេះ៖
**539 ÷ 4 = 134 សំណល់ 3**

ចូរធ្វើប្រមាណវិធីចែក និងបំពេញផលចែកក្នុងប្រអប់

មើលវីដេអូ

ក) 
530 | 3

ខ) 
774 | 5

គ) 
964 | 7

ឃ) 
823 | 4

ង) 
856 | 6

ច) 
958 | 8

## ហ្វឹកហាត់ការចែកចំនួនគត់មានលេខ 3ខ្ទង់នឹង 1ខ្ទង់មានសំណល់

មើលវីដេអូ

ចូរធ្វើប្រមាណវិធីចែក រួចស្វែងរកផលចែកនៅលើរូបភាព ហើយផាត់ពណ៌លើនៅលើផ្នែកនោះ និងបំពេញផលចែកក្នុងប្រអប់។ តើអ្នករកឃើញរូបភាពអ្វី? ______________________

ក) 874 | 3

ខ) 945 | 6

គ) 678 | 4

ឃ) 589 | 5




ង) 989 | 8

ច) 831 | 4

ឆ) 563 | 2

ជ) 824 | 7

# ការផ្ទៀងផ្ទាត់ផលចែកដោយប្រើវិធីគុណ

**គួរចងចាំ**

## ប្រមាណវិធី

```
 847 | 5
- 5  |----
     | 169
  34
- 30
  47
- 45
   2
```

847 ÷ 5 = **169** សំណល់ **2**

## ផ្ទៀងផ្ទាត់ផលចែក

**ជំហានទី១៖**
យកផលចែក គុណនឹងតួចែក។

```
  34
  169
x   5
  845
```

**ជំហានទី២៖**
បូកផលគុណជាមួយសំណល់។

845 + 2 = **847**




មើលវីដេអូ

1. ចូរផ្ទៀងផ្ទាត់ផលចែកដោយធ្វើប្រមាណវិធីគុណ និងបំពេញប្រអប់

**ឧទាហរណ៍**

643 ÷ 2 = 321 សំណល់ 1

```
  3 2 1
x     2
  6 4 2
```

642 + 1 = 643

ក) 857 ÷ 3 = 285 សំណល់ 2

```
  2 8 5
x     3
  [   ]
```

[   ] + [   ] = [   ]

ខ) 429 ÷ 5 = 85 សំណល់ 4 (ផលចែក) [   ]
(តួចែក) x [   ]
[   ]

[   ] + [   ] = [   ]

គ) 919 ÷ 9 = 102 សំណល់ 1 (ផលចែក) [   ]
(តួចែក) x [   ]
[   ]

[   ] + [   ] = [   ]

ឃ) 790 ÷ 8 = 98 សំណល់ 6
[   ]
x [   ]
[   ]

[   ] + [   ] = [   ]

ង) 807 ÷ 4 = 201 សំណល់ 3
[   ]
x [   ]
[   ]

[   ] + [   ] = [   ]

មើលវីដេអូ

2. ចូរផ្ទៀងផ្ទាត់ផលចែកដោយគូស ✓ ក្នុងប្រអប់ប្រសិនបើវាត្រឹមត្រូវ និងគូស **x** ប្រសិនបើវាមិនត្រឹមត្រូវ

ក) 17 ÷ 5 = 3 សំណល់ 2 [   ]  ខ) 37 ÷ 7 = 5 សំណល់ 3 [   ]  គ) 29 ÷ 8 = 3 សំណល់ 5 [   ]

ឃ) 40 ÷ 6 = 6 សំណល់ 4 [   ]  ង) 58 ÷ 9 = 7 សំណល់ 4 [   ]  ច) 39 ÷ 5 = 7 សំណល់ 4 [   ]

# មួយចំនួនចែកដាច់នឹងមួយចំនួនទៀត

1. ក) ជួយមនុស្សយន្តដោយជ្រើសរើសផលចែកនៅលើខ្លួនមនុស្សយន្តទៅនឹងល្បះលេខឱ្យបានត្រឹមត្រូវ៖

មើលវីដេអូ




តំណាំងចែក

| | |
|---|---|
| 40 ÷ 2 = | |
| 84 ÷ 2 = | |
| 248 ÷ 2 = | 124 |
| 412 ÷ 2 = | |
| 636 ÷ 2 = | |
| 500 ÷ 2 = | |

| | |
|---|---|
| 20 ÷ 5 = | 4 |
| 65 ÷ 5 = | |
| 360 ÷ 5 = | |
| 400 ÷ 5 = | |
| 575 ÷ 5 = | |
| 605 ÷ 5 = | |

ខ) ចូរស្វែងរក**តំណាំងចែក**ខាងលើដែលអាចចែកដាច់នឹង 2 និង5 រួចបំពេញក្នុងប្រអប់

ឧទាហរណ៍

40 ÷ 2 = 20

40 ÷ 5 = 8

☐ ÷ 2 = ☐ ☐ ÷ 2 = ☐

☐ ÷ 5 = ☐ ☐ ÷ 5 = ☐

☐ ÷ 2 = ☐ ☐ ÷ 2 = ☐

☐ ÷ 5 = ☐ ☐ ÷ 5 = ☐

គួរចងចាំ

**264 ÷ 3**

**ផលបូកតួលេខនៃតំណាំងចែក** 2 + 6 + 4 = 12

**ចែកដាច់នឹង** 3 12 ÷ 3 = 4 សំណល់ 0

**មួយចំនួនចែកដាច់នឹង 3 កាលណាផលបូកតួលេខនៃចំនួននោះចែកដាច់នឹង 3 ។**

**264 ÷ 3 = 88**




មើលវីដេអូ

2. ចូរគូស ✓ ក្នុងប្រអប់បើអំណះអំណាងនោះត្រឹមត្រូវ

| | | | | | |
|---|---|---|---|---|---|
| ក) | 658 ចែកដាច់នឹង 3 | X | ខ) | 423 ចែកដាច់នឹង 3 | |
| គ) | 765 ចែកដាច់នឹង 3 | | ឃ) | 329 ចែកដាច់នឹង 3 | |
| ង) | 1803 ចែកដាច់នឹង 3 | | ច) | 5462 ចែកដាច់នឹង 3 | |

# មួយចំនួនចែកដាច់នឹងមួយចំនួនទៀត (ត)

**គួរចងចាំ**

**348 ÷ 4**

**មើលទៅខ្ទង់ដប់និងខ្ទង់រាយ** **48**

**ចែកដាច់នឹង** 4 — 48 ÷ 4 = 12 សំណល់ 0

**មួយចំនួនចែកដាច់នឹង 4 កាលណាពីរតួលេខខាងចុងនៃចំនួននោះចែកដាច់នឹង 4 ។**

**348 ÷ 4 = 87**




1. ចូរគូស ✓ ក្នុងប្រអប់បើអំណះអំណាងនោះត្រឹមត្រូវ

ក) 316 ចែកដាច់នឹង 4 ☑ — ខ) 247 ចែកដាច់នឹង 3 ☐

គ) 753 ចែកដាច់នឹង 4 ☐ — ឃ) 472 ចែកដាច់នឹង 3 ☐

ង) 104 ចែកដាច់នឹង 4 ☐ — ច) 668 ចែកដាច់នឹង 3 ☐

មើលវីដេអូ

---

2. **ល្បែងស្វែងរកចំនួនចែកដាច់** (លេងជាដៃគូ)

**សម្ភារៈ៖** វត្ថុចំណាំម្នាក់ ៩គ្រាប់

**របៀបលេង៖**

១) ប្តូរវេនគ្នាបង្វិលថាសដើម្បីរកតួចែក។ រកមើលតំណាំងចែកនៅក្នុងប្រអប់របស់ខ្លួនដែលចែកដាច់នឹងតួចែកដែលបង្វិលបាននោះ។

២) ដាក់វត្ថុចំណាំលើចំនួននោះ។

៣) អ្នកដែលបានដាក់វត្ថុចំណាំលើចំនួនទាំងអស់មុនគេ គឺជា**អ្នកឈ្នះ**!

មើលវីដេអូ




តំណាំងចែកសម្រាប់សិស្ស **ក**

| | | |
|---|---|---|
| 36 | 14 | 12 |
| 40 | 21 | 28 |
| 18 | 15 | 20 |

តំណាំងចែកសម្រាប់សិស្ស **ខ**

| | | |
|---|---|---|
| 36 | 14 | 12 |
| 40 | 21 | 28 |
| 18 | 15 | 20 |

**ឧទាហរណ៍**




តួចែក 6
ប៉ាំងលេខ 12

| | | |
|---|---|---|
| 36 | 14 | ● |
| 40 | 21 | 28 |
| 18 | 15 | 20 |




តួចែក 7
ប៉ាំងលេខ 21

| | | |
|---|---|---|
| 36 | 14 | 12 |
| 40 | ● | 28 |
| 18 | 15 | 20 |

# មេរៀនទី 12 ប្រភាគ

## រំឭកអំពីប្រភាគពីថ្នាក់ទី ២

**គួរចងចាំ**

| រូបការេមួយចែកជា៖ | ពីរចំណែកស្មើគ្នា | បីចំណែកស្មើគ្នា | បួនចំណែកស្មើគ្នា |
|---|---|---|---|



| យើងសរសេរប្រភាគផ្នែកផាត់ពណ៌៖ | $\frac{1}{2}$ | $\frac{1}{3}$ | $\frac{1}{4}$ |
|---|---|---|---|
| យើងអានថា៖ | មួយភាគ**ពីរ** | មួយភាគ**បី** | មួយភាគ**បួន** |

មើលវីដេអូ

1. តើប្រភាគតាងឱ្យផ្នែកដែល**ផាត់ពណ៌**ត្រូវឬខុស? ចូរគូសសញ្ញា ✓ ឬ X ក្នុងរង្វង់

ឧទាហរណ៍



$\frac{1}{3}$ (X)



ក) $\frac{1}{3}$ ◯ ខ) $\frac{1}{2}$ ◯ គ) $\frac{1}{4}$ ◯ ឃ) $\frac{1}{2}$ ◯ ង) $\frac{1}{4}$ ◯

2. ចូរផាត់ពណ៌ចំណែករូបភាពឱ្យត្រូវនឹងប្រភាគដែលគេឱ្យ

ឧទាហរណ៍



$\frac{1}{3}$



ក) $\frac{1}{3}$ ខ) $\frac{1}{2}$ គ) $\frac{1}{4}$ ឃ) $\frac{1}{2}$ ង) $\frac{1}{3}$

3. ចូរគូសរង្វង់រូបភាពឱ្យត្រូវនឹងប្រភាគដែលគេឱ្យ

មើលវីដេអូ

ឧទាហរណ៍



$\frac{1}{4}$



$\frac{1}{3}$



$\frac{1}{2}$



$\frac{1}{3}$



$\frac{1}{4}$

$\frac{1}{2}$



# ហ្វឹកហាត់ប្រភាគ $\frac{1}{2}$ ; $\frac{1}{4}$ និង $\frac{1}{3}$

**ល្បែងប្រភាគរីករាយ** (លេងជាដៃគូ)

មើលវីដេអូ

**របៀបលេង៖**

អ្នកណាដែលញ៉ាំផ្លែប៉ោម និងនំអស់មុនគេ គឺជា**អ្នកឈ្នះ**!

១) ជ្រើសរើសប្រអប់ម្នាក់មួយ

២) ម្នាក់ៗប្ដូរវេនគ្នាបង្វិលថាស រួចផាត់ពណ៌ចំណែកនៃប្រភាគនោះ។ ប្រសិនបើចំណែកដែលបង្វិលបាននោះផាត់ពណ៌រួចហើយ ត្រូវប្ដូរវេនទៅឱ្យអ្នកបន្ទាប់។

៣) បន្តលេងរហូតដល់មានអ្នកណាម្នាក់បានផាត់ពណ៌គ្រប់ចំណែកទាំងអស់ មានន័យថាគេបានញ៉ាំផ្លែប៉ោម និងនំរបស់គេអស់ហើយ!

ឧទាហរណ៍









# ប្រភាគតូចជាងឯកតា

**គួរចងចាំ**




$\frac{2}{5}$ ភាគយក → ចំណែកដែលយកចេញពីចំណែកសរុប

ភាគបែង → ចំណែកសរុប

មើលវីដេអូ

1. ចូរសរសេរប្រភាគនៃរូបដែល**បានផាត់ពណ៌**

ឧទាហរណ៍



$\frac{5}{6}$ នៃ 6 គឺ 5



ក) $\frac{\square}{\square}$



ខ) $\frac{\square}{\square}$



គ) $\frac{\square}{\square}$



ឃ) $\frac{\square}{\square}$

2. **ល្បែងផាត់ពណ៌ប្រភាគ**

មើលវីដេអូ

**របៀបលេង៖**

១) បង្វិលថាសនិងសរសេរលទ្ធផលក្នុងប្រអប់**ភាគយក**

២) រាប់ចំនួនរូបភាពរួចសរសេរលទ្ធផលនៅក្នុងប្រអប់**ភាគបែង**

៣) ផាត់ពណ៌រូបភាពឱ្យត្រូវនឹងប្រភាគ

៤) រកអ្នកណាម្នាក់មកជួយផ្ទៀងផ្ទាត់ចម្លើយថាត្រូវឬខុស។




ឧទាហរណ៍




ក) $\frac{\square}{\square}$



ខ) $\frac{\square}{\square}$



គ) $\frac{\square}{\square}$





ឃ) $\frac{\square}{\square}$



ង) $\frac{\square}{\square}$

# ការសរសេរប្រភាគស្មើនឹងឯកតា

**គួរចងចាំ**

តើ**ប្រភាគ**តាងឱ្យផ្លែចេកដែលស្វាបានស៊ី គេសរសេរយ៉ាងដូចម្តេច?













**3** ← ភាគយក ប្រាប់ថា ស្វាស៊ីចេកអស់បីផ្លែ

**3** ← ភាគបែង ប្រាប់ថា ចេកសរុបមានបីផ្លែ

$\frac{3}{3}$ តាងឱ្យឯកតាទាំងមូលនៃផ្លែចេក (ប្រភាគស្មើឯកតា)

បើស្វាស៊ីចេកអស់ $\frac{3}{3}$ មានន័យថា**ស្វាបានស៊ីចេកទាំងអស់។**

មើលវីដេអូ

1. ចូរសរសេរប្រភាគដែលស្មើនឹងឯកតានៃផ្លែចេក រួចផាត់ពណ៌ចំនួនចេកដែលស្វាបានស៊ី

**ឧទាហរណ៍**



ប្រភាគស្មើឯកតា = $\frac{3}{3}$

ស្វាស៊ីអស់ = $\frac{2}{3}$

ក)



ប្រភាគស្មើឯកតា = $\frac{\square}{\square}$

ស្វាស៊ីអស់ = $\frac{1}{2}$

ខ)



ប្រភាគស្មើឯកតា = $\frac{\square}{\square}$

ស្វាស៊ីអស់ = $\frac{4}{5}$

គ)



ប្រភាគស្មើឯកតា = $\frac{\square}{\square}$

ស្វាស៊ីអស់ = $\frac{2}{4}$

មើលវីដេអូ

2. ចូរបំពេញប្រអប់ប្រភាគ រួចគូររូបផ្លែចេកឱ្យត្រូវនឹងប្រភាគនោះ បន្ទាប់មកផាត់ពណ៌ចំនួនចេកដែលស្វាបានស៊ី

**ឧទាហរណ៍**



ប្រភាគស្មើនឹងឯកតា = $\frac{3}{3}$

ស្វាស៊ីអស់ = $\frac{2}{3}$

ប្រភាគស្មើនឹងឯកតា = $\frac{\square}{\square}$

ស្វាស៊ីអស់ = $\frac{\square}{5}$

ប្រភាគស្មើនឹងឯកតា = $\frac{\square}{\square}$

ស្វាស៊ីអស់ = $\frac{\square}{7}$

3. ចំណោទ

លីដាមានផ្លែក្រូចចំនួន 9 ផ្លែ។  នាងបានចែកឱ្យមិត្តរបស់នាងចំនួន 4 ផ្លែ  ។

ចូរសរសេរប្រភាគតាងឱ្យចំនួនក្រូចដែលនាងបានចែកឱ្យដល់មិត្តរបស់នាង? $\frac{\square}{\square}$

# ការប្រៀបធៀបប្រភាគ

**គួរចងចាំ**





$\frac{1}{4}$ $\frac{1}{4}$ $\frac{1}{4}$ $\frac{1}{4}$

ផ្លែប៉ោម 1 ចែកជា 4 ចំណែកស្មើគ្នា ស្មើឯកតា $\frac{4}{4}$





$\frac{1}{4}$ $\frac{2}{4}$

យើងសរសេរ $\frac{1}{4} < \frac{2}{4}$ ឬ $\frac{2}{4} > \frac{1}{4}$



តិចជាង



$\frac{1}{4} < \frac{2}{4}$



ច្រើនជាង



$\frac{2}{4} > \frac{1}{4}$

មើលវីដេអូ

1. ចូរប្រៀបធៀបប្រភាគដោយប្រើសញ្ញា < > ឬ = ក្នុងរង្វង់

**ឧទាហរណ៍**



$\frac{4}{6}$ (>) $\frac{3}{6}$

ក)



$\frac{2}{8}$ ◯ $\frac{5}{8}$

ខ)



$\frac{4}{5}$ ◯ $\frac{3}{5}$

គ)



$\frac{9}{10}$ ◯ $\frac{9}{10}$

ឃ)



$\frac{3}{7}$ ◯ $\frac{2}{7}$

ង)



$\frac{6}{9}$ ◯ $\frac{7}{9}$

2. ចូរបង្កើតប្រភាគដោយផាត់ពណ៌លើរូប ដើម្បីប្រៀបធៀបដោយប្រើសញ្ញា < > ឬ =

**ឧទាហរណ៍**



$\frac{4}{8}$ (>) $\frac{2}{8}$

ក)



$\frac{\square}{\square}$ ◯ $\frac{\square}{\square}$

ខ)



$\frac{\square}{\square}$ ◯ $\frac{\square}{\square}$

គ)



$\frac{\square}{\square}$ ◯ $\frac{\square}{\square}$

ឃ)



$\frac{\square}{\square}$ ◯ $\frac{\square}{\square}$

# ការបូកប្រភាគមានភាគបែងដូចគ្នា

**គួរចងចាំ**

$\frac{1}{4} + \frac{1}{4} = \frac{\square}{\square}$

$\frac{1}{4} + \frac{1}{4} = \frac{1+1}{4} = \frac{2}{4}$




ដូចនេះ $\frac{1}{4} + \frac{1}{4} = \frac{2}{4}$




បូកភាគយកនឹងភាគយក ភាគបែងរក្សាដដែល។

1. ចូរបំពេញភាគយកក្នុងប្រអប់ឱ្យបានត្រឹមត្រូវ

$\frac{1}{4} + \frac{2}{4} = \frac{?}{4}$




$\frac{\square}{4} + \frac{2}{4} = \frac{\square + \square}{4} = \frac{\square}{4}$

ដូចនេះ $\frac{\square}{4} + \frac{\square}{4} = \frac{\square}{4}$

មើលវីដេអូ

2. ចូរបំពេញប្រអប់ប្រភាគរួច ធ្វើប្រមាណវិធី និងផាត់ពណ៌រូបភាពឱ្យត្រូវនឹងផលបូកនៃប្រភាគនោះ

**ឧទាហរណ៍**



$\frac{4}{8} + \frac{1}{8} = \frac{5}{8}$

ក)



$\frac{\square}{8} + \frac{\square}{8} = \frac{\square}{8}$

ខ)



$\frac{\square}{\square} + \frac{\square}{\square} = \frac{\square}{\square}$

គ)



$\frac{\square}{\square} + \frac{\square}{\square} = \frac{\square}{\square}$

មើលវីដេអូ

ឃ)



$\frac{\square}{\square} + \frac{\square}{\square} = \frac{\square}{\square}$

ង)



$\frac{\square}{\square} + \frac{\square}{\square} = \frac{\square}{\square}$

ច)



$\frac{\square}{\square} + \frac{\square}{\square} = \frac{\square}{\square}$

# ការដកប្រភាគមានភាគបែងដូចគ្នា

**គួរចងចាំ**





កូនស្វាឆ្លាតមាន ចេក 6 ផ្លែ។ ជាប្រភាគ $\frac{6}{6}$

កូនស្វាឆ្លាតស៊ីចេក អស់ 4 ផ្លែ។ ជាប្រភាគ $\frac{4}{6}$

តើយើងត្រូវសរសេរប្រភាគដើម្បីតាងឱ្យចំនួនចេកដែលនៅសល់?

$\frac{?}{6}$




$\frac{6}{6} - \frac{4}{6} = \frac{6-4}{6} = \frac{2}{6}$

ដូចនេះត្រូវសរសេរ $\frac{2}{6}$



$\frac{5}{8} - \frac{2}{8} = \frac{5-2}{8} = \frac{3}{8}$

ដូចនេះ: $\frac{5}{8} - \frac{2}{8} = \frac{3}{8}$

មើលវីដេអូ

1. ចូរបំពេញប្រអប់ប្រភាគ រួចធ្វើប្រមាណវិធី

ក)



$\frac{6}{8} - \frac{\square}{8} = \frac{\square - \square}{8} = \frac{\square}{8}$

ដូចនេះ: $\frac{\square}{8} - \frac{\square}{8} = \frac{\square}{8}$

ខ)



$\frac{5}{6} - \frac{\square}{6} = \frac{\square - \square}{6} = \frac{\square}{6}$

ដូចនេះ: $\frac{\square}{6} - \frac{\square}{6} = \frac{\square}{6}$

2. ចូរបំពេញប្រអប់ប្រភាគ រួចធ្វើប្រមាណវិធី

ក)



ខ)



គ)



ក) $\frac{3}{\square} - \frac{\square}{4} = \frac{\square - \square}{4} = \frac{\square}{4}$

ដូចនេះ: $\frac{\square}{\square} - \frac{\square}{\square} = \frac{\square}{\square}$

ខ) $\frac{6}{\square} - \frac{\square}{6} = \frac{\square - \square}{6} = \frac{\square}{6}$

ដូចនេះ: $\frac{\square}{\square} - \frac{\square}{\square} = \frac{\square}{\square}$

គ) $\frac{5}{\square} - \frac{\square}{7} = \frac{\square - \square}{7} = \frac{\square}{7}$

ដូចនេះ: $\frac{\square}{\square} - \frac{\square}{\square} = \frac{\square}{\square}$

# ហ្វឹកហាត់ការបូក និងដកប្រភាគមានភាគបែងដូចគ្នា

**គួរចងចាំ**





$\frac{2}{5} + \frac{2}{5} = \frac{4}{5}$ $\frac{1}{4} + \frac{2}{4} = \frac{3}{4}$

**បូកភាគយកនឹងភាគយក ភាគបែងរក្សាទុកដដែល។**



$\frac{8}{8} - \frac{3}{8} = \frac{5}{8}$






**ដកភាគយកនឹងភាគយក ភាគបែងរក្សាទុកដដែល។**

មើលវីដេអូ

1. ចូររកផលបូកប្រភាគខាងក្រោម

ក) $\frac{1}{3} + \frac{1}{3} = \frac{\square}{\square}$ ខ) $\frac{2}{5} + \frac{1}{5} = \frac{\square}{\square}$ គ) $\frac{3}{6} + \frac{2}{6} = \frac{\square}{\square}$ ឃ) $\frac{1}{9} + \frac{6}{9} = \frac{\square}{\square}$ ង) $\frac{3}{7} + \frac{3}{7} = \frac{\square}{\square}$

ច) $\frac{2}{4} + \frac{1}{4} = \frac{\square}{\square}$ ឆ) $\frac{4}{8} + \frac{1}{8} = \frac{\square}{\square}$ ជ) $\frac{1}{2} + \frac{1}{2} = \frac{\square}{\square}$ ឈ) $\frac{4}{10} + \frac{5}{10} = \frac{\square}{\square}$ ញ) $\frac{4}{8} + \frac{2}{8} = \frac{\square}{\square}$

2. ចូររកផលដកប្រភាគខាងក្រោម

ក) $\frac{6}{8} - \frac{2}{8} = \frac{\square}{\square}$ ខ) $\frac{3}{4} - \frac{1}{4} = \frac{\square}{\square}$ គ) $\frac{5}{6} - \frac{2}{6} = \frac{\square}{\square}$ ឃ) $\frac{7}{7} - \frac{4}{7} = \frac{\square}{\square}$ ង) $\frac{2}{3} - \frac{1}{3} = \frac{\square}{\square}$

ច) $\frac{8}{10} - \frac{3}{10} = \frac{\square}{\square}$ ឆ) $\frac{4}{5} - \frac{3}{5} = \frac{\square}{\square}$ ជ) $\frac{5}{7} - \frac{1}{7} = \frac{\square}{\square}$ ឈ) $\frac{8}{9} - \frac{2}{9} = \frac{\square}{\square}$ ញ) $\frac{7}{8} - \frac{3}{8} = \frac{\square}{\square}$

3. ចូរបំពេញប្រអប់ប្រភាគខាងក្រោម

**ឧទាហរណ៍**

$\frac{2}{6} + \frac{3}{6} = \frac{5}{6}$

ក) $\frac{3}{8} + \frac{\square}{\square} = \frac{7}{8}$ ខ) $\frac{2}{4} + \frac{\square}{\square} = \frac{3}{4}$ គ) $\frac{1}{7} + \frac{\square}{\square} = \frac{6}{7}$ ឃ) $\frac{4}{10} + \frac{\square}{\square} = \frac{10}{10}$

មើលវីដេអូ

4. ចូរបំពេញប្រអប់ប្រភាគខាងក្រោម

**ឧទាហរណ៍**

$\frac{4}{5} - \frac{2}{5} = \frac{2}{5}$

ក) $\frac{\square}{\square} - \frac{1}{4} = \frac{1}{4}$ ខ) $\frac{\square}{\square} - \frac{3}{8} = \frac{5}{8}$ គ) $\frac{\square}{\square} - \frac{2}{6} = \frac{3}{6}$ ឃ) $\frac{\square}{\square} - \frac{3}{10} = \frac{4}{10}$

5. ចំណោទ កូនស្វាឆ្លាតមានចេក 4 ផ្លែ។ វាបានស៊ីអស់ 1 ផ្លែ។
តើស្វានៅសល់ចេកប៉ុន្មានផ្លែទៀត? ចូរសរសេរជាប្រភាគ។

$\frac{4}{4} - \frac{\square}{\square} = \frac{\square}{\square}$



# មេរៀនទី 13 ក្រាបរូបភាព លំនាំគំរូ ឱកាស

## បកស្រាយក្រាបរូបភាព

1. ចូរមើលក្រាបរូបភាពបង្ហាញពីចំនួនស្បែកជើងដែលរោងចក្រផលិតបាន និងឆ្លើយសំណួរខាងក្រោម

| ខែ | ចំនួនស្បែកជើង |
|---|---|
| មេសា |  |
| ឧសភា |  |
| មិថុនា |  |



តាងស្បែកជើង 100គូ។

មើលវីដេអូ

ក) តើនៅខែ**មិថុនា**រោងចក្រផលិតស្បែកជើងបានចំនួនប៉ុន្មានគូ?

ខ) តើនៅខែណាដែលរោងចក្រផលិតស្បែកជើងបាន**ច្រើនជាងគេ**?

គ) តើនៅខែ**មេសា** និងខែ**មិថុនា** រោងចក្រផលិតស្បែកជើងសរុបបានចំនួនប៉ុន្មានគូ?

ឃ) តើនៅខែ**ឧសភា**រោងចក្រផលិតស្បែកជើងបានច្រើនជាងខែ**មិថុនា**ចំនួនប៉ុន្មានគូ?

ង) តើរោងចក្រផលិតស្បែកជើងសរុបបានចំនួនប៉ុន្មានគូ?

មើលវីដេអូ

---

**រូបធរណីមាត្រដែលកុមារចូលចិត្ត**




▬ នីមួយៗតាងកុមារ 5នាក់។

▲ នីមួយៗតាងកុមារ 5នាក់។

■ នីមួយៗតាងកុមារ 5នាក់។

○ នីមួយៗតាងកុមារ 5នាក់។

2. ចូរមើលក្រាបរូបភាព និងឆ្លើយសំណួរខាងក្រោម

ក) តើមានកុមារប៉ុន្មាននាក់ដែលចូលចិត្ត ▲?

ខ) តើរូបធរណីមាត្រមួយណាដែលកុមារចូលចិត្ត តិចជាងគេ?

គ) តើកុមារដែលចូលចិត្ត ▬ ច្រើនជាងកុមារ ដែលចូលចិត្ត ○ ចំនួនប៉ុន្មាននាក់?

ឃ) តើមានកុមារប៉ុន្មាននាក់ចូលចិត្ត ■?

ង) តើកុមារដែលចូលចិត្ត ▲ តិចជាងកុមារដែល ចូលចិត្ត ■ ចំនួនប៉ុន្មាននាក់?

ច) តើកុមារដែលចូលចិត្ត ○ និង ▬ មានចំនួន ប៉ុន្មាននាក់?

ឆ) តើមានកុមារសរុបមានចំនួនប៉ុន្មាននាក់?

# ការសង់ និងបកស្រាយក្រាបរូបភាព

1. ចូរសង់ក្រាបរូបភាពដោយប្រើទិន្នន័យខាងក្រោម

**ប្រភេទទិន្នន័យ៖** ទំនិញបួនមុខដែលអាជីវករលក់អស់ក្នុងមួយថ្ងៃ។

**ទិន្នន័យដែលប្រមូលបាន៖** ប័រ 60kg; ក្រូច 40kg; ត្រី 70kg; ការ៉ុត 50kg



មើលវីដេអូ

ទម្ងន់គិតជា kg



មាត្រដ្ឋាន

 តាង ☐ kg

 តាង ☐ kg

 តាង ☐ kg

 តាង ☐ kg

2. ចូរឆ្លើយសំណួរដោយប្រើក្រាបរូបភាពខាងលើ

ក) តើអ្នកបានដាក់ចំណងជើងក្រាបថាដូចម្តេច?

ខ) តើគេលក់ផ្លែក្រូចអស់ចំនួនប៉ុន្មានគីឡូក្រាម?

គ) តើអ្នកប្រើរូបមួយតាងឱ្យទម្ងន់នវត្ថុប៉ុន្មានគីឡូក្រាម?

ឃ) តើគេលក់ត្រីអស់ច្រើនជាងផ្លែប័រចំនួនប៉ុន្មានគីឡូក្រាម?

ង) តើទំនិញសរុបមានចំនួនប៉ុន្មានគីឡូក្រាម?

ច) តើគេលក់ការ៉ុតអស់តិចជាងត្រីចំនួនប៉ុន្មានគីឡូក្រាម?

# ការសង់ក្រាបរូបភាពដោយប្រើទិន្នន័យតែមួយ

**គួរចងចាំ**

មីងលីជាជាអ្នកលក់បន្លែ៖



នៅថ្ងៃអាទិត្យ គាត់លក់ការ៉ុតអស់ **30kg** និងខ្ទឹមបារាំងអស់ **20kg**។

នៅថ្ងៃចន្ទ គាត់លក់ការ៉ុតអស់ **20kg** និងខ្ទឹមបារាំងអស់ **30kg**។

នៅថ្ងៃអង្គារ គាត់លក់ការ៉ុតអស់ **10kg** និងខ្ទឹមបារាំងអស់ **40kg**។



**ប្រភព៖** ការ៉ុត និងខ្ទឹមបារាំងដែលមីងលីជាបានលក់រយៈពេល 3ថ្ងៃ។

**ទិន្នន័យ៖** ទម្ងន់នៃការ៉ុត និងខ្ទឹមបារាំងដែលគាត់បានលក់។

**ក្រាបមានរូបភាព**

បន្លែដែលបានលក់




**ក្រាបគ្មានរូបភាព**

បន្លែដែលបានលក់




មើលវីដេអូ

ចូរសង់ក្រាបរូបភាពដោយប្រើទិន្នន័យខាងក្រោម

ចំនួនសិស្សដែលចូលអានសៀវភៅនៅបណ្ណាល័យមួយក្នុងរយៈពេល 3សប្ដាហ៍៖ **សប្ដាហ៍ទី១៖** ស្រី 30នាក់ ប្រុស 20នាក់ **សប្ដាហ៍ទី២៖** ស្រី 40នាក់ ប្រុស 30នាក់ **សប្ដាហ៍ទី៣៖** ស្រី 20នាក់ ប្រុស 40នាក់។

ចំនួនសិស្សដែលចូលបណ្ណាល័យ






# ហ្វឹកហាត់ការសង់ក្រាបរូបភាពដោយប្រើទិន្នន័យតែមួយ

| | |
|---|---|
| ដំរី | \|\|\|\|\| |
| ស្វា | \|\|\|\|\|\| |
| ផ្សោត | \|\|\|\|\| |
| ខ្លា | \|\|\|\| |

1. ចូរសង់ និងបកស្រាយក្រាបដោយប្រើទិន្នន័យដែលផ្តល់ឱ្យ

**ប្រភព៖** ការចូលចិត្តរបស់សិស្សថ្នាក់ទី៣ ទៅលើសត្វដំរី ស្វា ផ្សោត និងខ្លា។

**ទិន្នន័យ៖** កត់ត្រាដោយប្រើគំនូសតាងនៅលើក្តារឆ្នួន។




ចំនួនសិស្ស

| | | | | |
|---|---|---|---|---|
| 6 | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | ដំរី | ស្វា | ផ្សោត | ខ្លា |




មើលវីដេអូ

2. ចូរសង់ និងបកស្រាយក្រាបដោយប្រើទិន្នន័យដែលផ្តល់ឱ្យ

**ប្រភព៖** ចំនួនសៀវភៅនៅលើធ្នើរបួនក្នុងបណ្ណាល័យមួយ។

**ទិន្នន័យ៖** **ធ្នើរទី១** មានសៀវភៅ 15ក្បាល **ធ្នើរទី២** មានសៀវភៅ 30ក្បាល

**ធ្នើរទី៣** មានសៀវភៅ 40ក្បាល **ធ្នើរទី៤** មានសៀវភៅ 25ក្បាល

**សម្គាល់៖** ប្រឡោះនីមួយៗតាងសៀវភៅ **10ក្បាល**។



មើលវីដេអូ

| | | | | |
|---|---|---|---|---|
| 40 | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | **ធ្នើរទី១** | **ធ្នើរទី២** | **ធ្នើរទី៣** | **ធ្នើរទី៤** |

# លំនាំគំរូស្ទួន និងលំនាំគំរូពង្រីក

**គួរចងចាំ**

**លំនាំគំរូស្ទួន**



មើលលំនាំគំរូ … លំនាំគំរូបន្ត

**លំនាំគំរូពង្រីក**



មើលលំនាំគំរូ … លំនាំគំរូបន្ត

មើលវីដេអូ

1. ចូរបំពេញលំនាំគំរូ ( លំនាំគំរូស្ទួន )

ក)  ☐

ខ)  ☐

គ) X ✓ ↓ ; X ✓ ↓ ; X ☐ ↓ ; X ✓ ☐ ; ☐ ✓ ☐

ឃ) 4702 ; 4702 ; 47☐2 ; ☐70☐ ; ☐☐0☐ ; ☐☐☐☐

2. ចូរបំពេញលំនាំគំរូ ( លំនាំគំរូពង្រីក )

ក)  ☐

ខ)  ☐

គ) 200 ; 203 ; 206 ; 20☐ ; 2☐2 ; 2☐☐ ; ☐☐8 ; ☐☐☐

ឃ) 1 + 2 = 3 ; 3 + ☐ = 5 ; 5 + ☐ = 7 ; ☐ + ☐ = 9 ; ☐ + ☐ = ☐

3. ចូរបង្កើតលំនាំគំរូមួយដោយខ្លួនឯង អាចជាលំនាំគំរូស្ទួនក៏បាន ឬលំនាំគំរូពង្រីកក៏បាន

# ឱកាសក្នុងជីវភាពរស់នៅ

**គួរចងចាំ**




នឹងកើតឡើង



មិនអាចកើតឡើង



អាចកើតឡើង

**ល្បែងពណ៌នារូបភាព** (លេងជាដៃគូ ឬក្រុមតូច)

**របៀបលេង៖**

១) ប្តូរវេនគ្នាបង្វិលថាសម្តងម្នាក់ រួចអានពាក្យដែលបង្វិលបាន។

២) ជ្រើសរើសរូបភាពដែលត្រូវគ្នាជាមួយពាក្យដែលបង្វិលបាន។

៣) ទាំងអស់គ្នាផ្ទៀងផ្ទាត់និងពណ៌នាអំពីរូបភាពនោះ។









មើលវីដេអូ



















# ចម្លើយសម្រាប់សៀវភៅលំហាត់ ប៤

## មេរៀនទី 11 វិធីចែក

**ទំព័រ១**

១) 8 ២) 6 ៣) 7 ៤) 5 ៥) 4

**ទំព័រ២**

1. ក) តួចែក ខ) តំណាំងចែក ផលចែក សំណល់

គ) តំណាំងចែក តួចែក ផលចែក សំណល់

ឃ) តំណាំងចែក ផលចែក

2. ក) 20 ÷ 4 = 5

```
 20 | 4
-20 | 5
 ---
  0
```

ខ)

```
 60 | 10
-60 | 6
 ---
  0
```

60 ÷ 10 = 6

គ) 16 ÷ 8 = 2

```
 16 | 8
-16 | 2
 ---
  0
```

**ទំព័រ៣**

| | | | |
|---|---|---|---|
| 1. ក) 4 | 2. ក) 2 | 3. ក) 6 | 4. ក) 6 |
| ខ) 6 | ខ) 4 | ខ) 9 | ខ) 10 |
| គ) 1 | គ) 7 | គ) 9 | គ) 7 |
| ឃ) 3 | ឃ) 5 | ឃ) 1 | ឃ) 9 |
| ង) 8 | ង) 9 | ង) 8 | ង) 8 |
| ច) 5 | ច) 6 | ច) 3 | ច) 7 |
| ឆ) 10 | ឆ) 1 | ឆ) 9 | ឆ) 10 |

**ទំព័រ៤**

| | | | |
|---|---|---|---|
| 1. ក) 2 | 2. ក) 4 | 3. ក) 6 | 4. ក) 15 |
| ខ) 5 | ខ) 7 | ខ) 7 | ខ) 6 |
| គ) 8 | គ) 2 | គ) 8 | គ) 6 |
| ឃ) 4 | ឃ) 10 | ឃ) 4 | ឃ) 5 |
| ង) 3 | ង) 1 | ង) 2 | ង) 9 |
| ច) 6 | ច) 5 | ច) 5 | ច) 6 |
| ឆ) 9 | ឆ) 2 | ឆ) 7 | ឆ) 3 |
| ជ) 2 | ជ) 9 | ជ) 4 | ជ) 7 |
| ឈ) 10 | ឈ) 3 | ឈ) 9 | ឈ) 8 |

**ទំព័រ៥**

1. ក) 8 ខ) 6 គ) 7 ឃ) 9
ង) 4 ច) 1 ឆ) 6 ជ) 3
ឈ) 10 ញ) 7 ដ) 9 ឋ) 2

2. ក) 2 ខ) 6 គ) 5 ឃ) 4
ង) 7 ច) 8 ឆ) 4 ជ) 9
ឈ) 9 ញ) 6 ដ) 8 ឋ) 8

**ទំព័រ៦**

2. ក) ✓ ខ) X គ) X ឃ) ✓ ង) ✓ ច) ✓
ឆ) ✓ ជ) X ឈ) X ញ) ✓ ដ) ✓ ឋ) X

**ទំព័រ៧**

ក) 43 ខ) 24 គ) 12 ឃ) 14
ង) 17 ច) 23 ឆ) 12 ជ) 27

**ទំព័រ៨**

ក) 39 ខ) 13 គ) 14 ឃ) 28

**ទំព័រ៩**

1. ក) 4 សំណល់ 2 ខ) 6 សំណល់ 3
គ) 8 សំណល់ 4 ឃ) 5 សំណល់ 1
ង) 3 សំណល់ 5 ច) 3 សំណល់ 2
ឆ) 5 សំណល់ 7 ជ) 6 សំណល់ 2
ឈ) 7 សំណល់ 7 ញ) 7 សំណល់ 4

2. ១) ក) 5ចូ ខ) 2ទង
២) ក) 6នាក់ ខ) 4គីឡូក្រាម

**ទំព័រ១០**

1. ក) 25 សំណល់ 1 ខ) 14 សំណល់ 1
គ) 21 សំណល់ 2 ឃ) 17 សំណល់ 4
ង) 13 សំណល់ 6 ច) 38 សំណល់ 1
ឆ) 29 សំណល់ 2 ជ) 18 សំណល់ 3

**ទំព័រ១២**

1. ក) 129 ខ) 122 គ) 178 ឃ) 316 ង) 128
ច) 235 ឆ) 121 ជ)156 ឈ) 287

**ទំព័រ១៣**

1. ក) 107 ខ) 236 គ) 126 ឃ) 336
ង) 127 ច) 106 ឆ) 256 ជ) 325
ចំនួនដែលនៅសល់គឺ 126

**ទំព័រ១៤**

1. ក) 176 សំណល់ 2 ខ) 154 សំណល់ 4
គ) 137 សំណល់ 7 ឃ) 205 សំណល់ 3
ង) 142 សំណល់ 4 ច) 119 សំណល់ 6

**ទំព័រ១៥**

1. ក) 291 សំណល់ 1 ខ) 157 សំណល់ 3
គ) 169 សំណល់ 2 ឃ) 117 សំណល់ 4
ង)123 សំណល់ 5 ច) 207 សំណល់ 3
ឆ) 281 សំណល់ 1 ជ) 117 សំណល់ 5

**ទំព័រ១៦**

1. ក) 285 x 3 = 255 ; 855 + 2 = 857

**ទំព័រ១៦**

ខ) 85 x 5 = 425 ; 425 + 4 = 429

គ) 102 x 9 = 918 ; 918 + 1 = 919

ឃ) 98 x 8 = 784 ; 784 + 6 = 790

ង) 201 x 4 = 804 ; 804 + 3 = 807

2. ក) ✓ ខ) X គ) ✓ ឃ) ✓ ង) X ច) ✓

**ទំព័រ១៧**

1. ក)

| | |
|---|---|
| 40 ÷ 2 = | 20 |
| 84 ÷ 2 = | 42 |
| 248 ÷ 2 = | 124 |
| 412 ÷ 2 = | 206 |
| 636 ÷ 2 = | 318 |
| 500 ÷ 2 = | 250 |

| | |
|---|---|
| 20 ÷ 5 = | 4 |
| 65 ÷ 5 = | 13 |
| 360 ÷ 5 = | 72 |
| 400 ÷ 5 = | 80 |
| 575 ÷ 5 = | 115 |
| 605 ÷ 5 = | 121 |

ខ) 80 ÷ 2 = 40 20 ÷ 2 + 10
80 ÷ 5 = 16 20 ÷ 5 = 2
250 ÷ 2 = 125
250 ÷ 5 = 50

2. ក) X ខ) ✓ គ) ✓ ឃ) X ង) ✓ ច) X

**ទំព័រ១៨**

1. ក) ✓ ខ) X គ) X ឃ) ✓ ង) ✓ ច) ✓

## មេរៀនទី 12 ប្រភាគ

**ទំព័រ១៩**

1. ក) ✓ ខ) ✓ គ) X ឃ) X ង) ✓

2. ក) ខ) គ) ឃ) ង)



# ចម្លើយសម្រាប់សៀវភៅលំហាត់ ប៤

### ទំព័រ១៩

3. 

### ទំព័រ២១

1. ក) $\frac{3}{4}$ ខ) $\frac{6}{8}$ គ) $\frac{1}{4}$ ឃ) $\frac{7}{10}$

### ទំព័រ២២

1. ក) $\frac{2}{2}$ ខ) $\frac{5}{5}$ គ) $\frac{4}{4}$



3. $\frac{4}{9}$

### ទំព័រ២៣

1. ក) < ខ) > គ) = ឃ) > ង) <

### ទំព័រ២៤

1. $\frac{1}{4} + \frac{2}{4} = \frac{1+1}{4} = \frac{2}{4}$

ដូចនេះ: $\frac{1}{4} + \frac{1}{4} = \frac{2}{4}$

2. ក) $\frac{2}{8} + \frac{4}{8} = \frac{6}{8}$ ខ) $\frac{3}{9} + \frac{4}{9} = \frac{7}{9}$

គ) $\frac{5}{10} + \frac{4}{10} = \frac{9}{10}$ ឃ) $\frac{2}{6} + \frac{2}{6} = \frac{4}{6}$

ង) $\frac{3}{8} + \frac{2}{8} = \frac{5}{8}$ ច) $\frac{1}{7} + \frac{3}{7} = \frac{4}{7}$

### ទំព័រ២៥

1. ក) $\frac{6}{8} - \frac{1}{8} = \frac{6+1}{8} = \frac{5}{8}$

ដូចនេះ: $\frac{6}{8} - \frac{1}{8} = \frac{5}{8}$

ខ) $\frac{5}{6} - \frac{2}{6} = \frac{5+2}{6} = \frac{3}{6}$

ដូចនេះ: $\frac{5}{6} - \frac{2}{6} = \frac{3}{6}$

### ទំព័រ២៥

2. ក) $\frac{3}{4} - \frac{1}{4} = \frac{3-1}{4} = \frac{2}{4}$

ដូចនេះ: $\frac{3}{4} - \frac{1}{4} = \frac{2}{4}$

ខ) $\frac{6}{6} - \frac{2}{6} = \frac{6-2}{6} = \frac{4}{6}$

ដូចនេះ: $\frac{6}{6} - \frac{2}{6} = \frac{4}{6}$

គ) $\frac{5}{7} - \frac{3}{7} = \frac{5-3}{7} = \frac{2}{7}$

ដូចនេះ: $\frac{5}{6} - \frac{3}{6} = \frac{2}{6}$

### ទំព័រ២៦

1. ក) $\frac{2}{3}$ ខ) $\frac{3}{5}$ គ) $\frac{5}{6}$ ឃ) $\frac{7}{9}$ ង) $\frac{6}{7}$

ច) $\frac{3}{4}$ ឆ) $\frac{5}{8}$ ជ) $\frac{2}{2}$ ឈ) $\frac{9}{10}$ ញ) $\frac{6}{8}$

2. ក) $\frac{4}{8}$ ខ) $\frac{2}{4}$ គ) $\frac{3}{6}$ ឃ) $\frac{3}{7}$ ង) $\frac{1}{3}$

ច) $\frac{5}{10}$ ឆ) $\frac{1}{5}$ ជ) $\frac{4}{7}$ ឈ) $\frac{6}{9}$ ញ) $\frac{4}{8}$

3. ក) $\frac{4}{8}$ ខ) $\frac{1}{4}$ គ) $\frac{5}{7}$ ឃ) $\frac{6}{10}$

4. ក) $\frac{2}{4}$ ខ) $\frac{8}{8}$ គ) $\frac{5}{6}$ ឃ) $\frac{7}{10}$

5. $\frac{4}{4} - \frac{1}{4} = \frac{3}{4}$

## មេរៀនទី 13 ក្រាបរូបភាព លំនាំគំរូ ឱកាស

### ទំព័រ២៧

1. ក) 400គូ

ខ) ខែឧសភា

គ) 900គូ

ឃ) 200គូ

ង) 1500គូ



### ទំព័រ២៧

2. ក) 20នាក់

ខ) ត្រីកោណ

គ) 15នាក់

ឃ) 50នាក់

ង) 30នាក់

ច) 65នាក់

### ទំព័រ២៩





### ទំព័រ៣០

1. 

2. 

### ទំព័រ៣១

1. ក) 

ខ) 

គ) X ✓ ↓ ; X ✓ ↓ ; X ✓ ↓

ឃ) 4702 ; 4702 ; 4702 ; 4702

2. ក) 

ខ) 

គ) 206 ; 212 ; 215 ; 218 ; 221

ឃ) 3 + 2 = 5 ; 5 + 2 = 7 ; 7 + 2 = 9 ; 9 + 2 = 11

# កូនស្វាឆ្លាតជួយកូនអ្នកឱ្យចេះគិតលេខបានរហ័ស!

កុមាររៀន កុមារចេះ ១ ២៣

ស្កេនដើម្បីមើលវីដេអូ
ការប្រើប្រាស់កូដ QR
នៅក្នុងសៀវភៅនេះ!



https://kounsvachhlat.com

## មានវីដេអូសម្រាប់រៀនធ្វើលំហាត់នីមួយៗ

គ្រប់លំហាត់ និងផ្នែកគួរចងចាំនៃមេរៀននីមួយៗនៅក្នុងសៀវភៅលំហាត់ **កូនស្វាឆ្លាត** សុទ្ធតែមានកូដ QR ( ) ដែលផ្ដល់នូវភាពងាយស្រួលក្នុងការចូលមើលវីដេអូ អំពីរបៀបធ្វើលំហាត់ទាំងនោះ ឬដើម្បីរំឭកមេរៀនឡើងវិញ។



អ្នកអាចមើលវីដេអូនៅលើទូរសព្ទគ្រប់ប្រភេទបានដោយគ្រាន់តែបើកកាមេរ៉ា ឬកម្មវិធីស្កេនកូដ QR ណាមួយ ហើយតម្រង់កាមេរ៉ាទៅរកកូដ QR ( ) ដែលមានស្រាប់ក្នុងសៀវភៅ។



**ភាសាខ្មែរ**



ថ្នាក់ទី១ ឆមាសទី១



ថ្នាក់ទី១ ឆមាសទី២



មត្តេយ្យ កម្រិតទាប



មត្តេយ្យ កម្រិតខ្ពស់

**គណិតវិទ្យា**



ថ្នាក់ទី១



ថ្នាក់ទី២



ថ្នាក់ទី៣



មត្តេយ្យ

GPE Transforming Education
unesco
វិទ្យាស្ថានបើកទូលាយ Open Institute
បោះពុម្ពឆ្នាំ ២០២៣
9 789924 578383